ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៤០០៩...សហវ.អលសា

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧

**ជម្រាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កម្មវត្ថុ :** ករណីសំណើសុំអនុម័តលទ្ធផលចរចាថ្លៃ និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុន Richgrid Technology លើថ្លៃសេវាទីប្រឹក្សាសម្រាប់ការងារសាងសង់សារមន្ទីរវារីអគ្គិសនីនៅស្រុកទឹកឈូ ខេត្តកំពត មានទឹកប្រាក់សរុប ៧% នៃតម្លៃដេញថ្លៃសរុប ។

**យោង :** - លិខិតលេខ ៣៦៥២ សហវ.អលសា ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ របស់អគ្គិសនីកម្ពុជា
- លិខិតលេខ ៧៤៧៣ លស.អក.លក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ របស់អគ្គិសនីកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយល់ព្រមតាមសំណើរបស់អគ្គិសនីកម្ពុជា ប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន Richgrid Technology លើថ្លៃសេវាទីប្រឹក្សាសម្រាប់ការងារសាងសង់សារមន្ទីរវារីអគ្គិសនីនៅស្រុកទឹកឈូ ខេត្តកំពត ក្នុងតម្លៃសរុបចំនួន ៧% នៃតម្លៃដេញថ្លៃសរុប (ប្រាំពីរភាគរយ) ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមប្រតិភូទទួលនូវការរាប់អានពីខ្ញុំ ។

ស. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អនុរដ្ឋលេខាធិការ

ហ៊ីង សុខណ្ណ

**ចម្លងជូន:**
-អគ្គនាយកដ្ឋានពន្ធដារ
-ក្រុមហ៊ុន Richgrid Technology
-ឯកសារ-កាលប្បវត្តិ